| | | | | | |
|---|---|---|---|---|---|
| ១២ | ប្រាក់ឧបត្ថម្ភ សំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល | - | ២៦.០០០ | - | ២៦.០០០ |
| ៩៣ | ការរំលស់បំណុល | - | ២៥.០០០ | - | ២៥.០០០ |

**មាត្រា ២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និងវាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០០១ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែមករា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

## អនុក្រឹត្យលេខ ០៤ អនក្រ.បក

## ស្តីពីការកាត់បន្ថយដែនសេវាឧក្ខនានីឡូត៍សេវាន ខេត្ត កំពង់ធំ ទុកសំរាប់ប្រជាពលរដ្ឋធ្វើសេវានជាលក្ខណៈគ្រួសារ

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល

-បានឃើញអនុក្រឹត្យលេខ ១៧/អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១.-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រ.កកសក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ដីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុង ទុកនៅទឹកសាបក្នុងខេត្ត កំពង់ធំ ដោយកាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តកំពង់ធំ និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយនេះ ។

**តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្ត កំពង់ធំ ដែលត្រូវកាត់បន្ថយ**

ឯកតា ហិកតា

| ប្រភេទ និងលេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃកាត់ចេញ គិតជាភាគរយ | ផ្ទៃឡូត៍ នេសាទនៅសល់ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |
| ១ | ៣០.២៤៥ | ២៧.៥៦១ | ៩១.១៣ | ២.៦៨៤ | |
| ២ | ១.៣១១ | ៣៩០ | ២៩.៧៥ | ៩២១ | |
| ៣ | ១៣.៥៤១ | ៧.៣៩៦ | ៥៤.៦២ | ៦.១៤៥ | |

| | | | | | |
|---|---|---|---|---|---|
| ៤ | ១៩.៣៩០ | ៧.២៧១ | ៣៧.១៩ | ១២.១៧៩ | |
| ៥ | ៩ ៥០៨ | ១.០៣៧ | ១០.៤៧ | ៨.៨៧១ | |
| ៦ | ២៥.៩០៥ | ១៣.៨៧៣ | ៥៣.៥៥ | ១២.០៣២ | |
| ៧ | ២៦.៨២៦ | ៣០៥ | ១.១៤ | ២៦.៥២១ | |
| **សរុប ៧** | **១២៧.១២៦** | **៥៧.៧៧៣** | **៩៥.៩៥** | **៦៩.៣៥៣** | |

**មាត្រា ២.-**

ដែននេសាទដែលបានកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុំព័ទ្ធយកទៅលក់ ឬជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទដើម្បីគ្រប់គ្រងកន្លែងដែលកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្ត កំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**